មជ្ឈមណ្ឌលឯកសារកម្ពុជា

# សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេចពីទោសរបស់ ឌុច

លីម ជ័យទ័ត្ត

ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងប្រកាសសាលដីកាលើសំណុំរឿង០០១ ករណីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាលដីកាអង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេចពីទោសរបស់ ឌុច ថាតើនឹងត្រូវបន្ថែមទោស ឬត្រូវសម្រាលទោសកម្រិតណា ។

សេចក្តីសម្រេចនៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល នឹងឆ្លើយតបទៅនឹងពាក្យបណ្តឹងសាទុក្ខរបស់ សហព្រះរាជអាជ្ញា ជនជាប់ចោទ ឌុច និងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។

បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដែលបានដាក់ជូនទៅអង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ បានសំអាងថា អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ស្ថានទម្ងន់គ្រប់គ្រាន់ក្នុងការផ្តន្ទាទោសលើជនជាប់ចោទ និងបានផ្តល់ស្ថានសម្រាលទោសហួសហេតុ ។ ឌុច គួរតែត្រូវផ្តន្ទាទោសបន្ថែមចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាអាទិ៍ ការដាក់ឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្មការរំលោភលើផ្លូវភេទ ការសម្លាប់រង្គាល និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ ។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ មេធាវីការពារក្តីឲ្យជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងគោលបំណងចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលលើកលែងការចោទប្រកាន់ទៅលើកូនក្តីរបស់ខ្លួន ដោយអះអាងថា ឌុច មិនបានស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ម្យ៉ាងទៀត ការផ្តន្ទាទោស ឌុច គួរតែអនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ។

រីឯ ដើមបណ្តឹងរដ្ឋប្បវេណីបីក្រុមក្នុងចំណោមបួនក្រុម បានដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានច្រានចោលសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន និងស្នើសុំឲ្យមានការផ្តល់នូវសំណងផ្លូវចិត្ត និងសំណងសមូហភាពដែលមានលក្ខណៈសមរម្យទៅតាមការចង់បានរបស់ជនរងគ្រោះ ។

អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចផ្ដន្ទាទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ។ ក៏ប៉ុន្តែទោសនេះ ត្រូវបានកាត់បន្ថយរយៈពេល៥ឆ្នាំ ជាការទូទាត់ចំពោះការឃុំឃាំងជនជាប់ចោទដោយខុសនីតិវិធីច្បាប់ដោយតុលាការយោធា និងរយៈពេល១១ឆ្នាំដែលឌុចត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងពន្ធនាគាររបស់តុលាការយោធា និងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល នឹងក្លាយទៅជាការបើកទំព័រប្រវត្តសាស្រ្តថ្មីមួយសម្រាប់ប្រទេសកម្ពុជា ហើយក៏នឹងក្លាយជាសេចក្ដីសម្រេចចុងក្រោយលើកដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានសម្រេចពីជោគវាសនារបស់អ្នកទទួលខុសត្រូវមួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ។